**Harold J. Bursztajn, MD**

សាកលវិទ្យាល័យ Princeton AB 1972

សាលាវេជ្ជសាស្ត្រ Havard MD 1976

អាសយដ្ឋាន៖ 96 Larchwood Drive

Cambridge, MA 02138

ទូរស័ព្ទ៖ 617-492-8366

ទូរសារ៖ 617-441-3195

គេហទំព័រ៖ http://www.forensic-psych.com

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Nov-2012, 14:10
CMS/CFO: Sann Rada

ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២

អាង ឧត្តម

Michael G. Karnavas

អ.វ.ត.ក, ផ្លូវជាតិលេខ ៤, ចោមចៅ

ប្រអប់សំបុត្រ PO Box 71

ភ្នំពេញ

កម្ពុជា

កម្មវត្ថុ៖ **អៀង សារី**

ជូនចំពោះលោក អាង និងលោក Karnavas ៖

តាមរយៈសំណើរបស់លោក ខ្ញុំបានធ្វើការសិក្សាជាបឋមមួយអំពីរបាយការណ៍របស់វេជ្ជបណ្ឌិត Campbell ស្តីពីការព្យាយាមវាយតម្លៃផ្នែកវិកលវិទ្យានីតិវេជ្ជសាស្ត្រទៅលើសមត្ថភាពរបស់ អៀង សារី ដើម្បីចូលរួមសវនាការ ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។

ជាការពិតជាក់ស្តែងដែលថាវិធីសាស្ត្ររបស់វេជ្ជបណ្ឌិត Campbell ក្នុងការវាយតម្លៃវិកលវិទ្យានីតិវេជ្ជសាស្ត្រអំពីសមត្ថភាពដើម្បីចូលរួមសវនាការ គឺពុំស្របតាមបទដ្ឋានដែលបានការទទួលស្គាល់ជាទូទៅឡើយ ដោយរាប់បញ្ចូលនូវចំណុចមួយចំនួនដូចខាងក្រោម៖

Original EN: 00859196-00859197

១. គាត់ពុំបានធ្វើតេស្ដ៍សមត្ថភាពផ្លូវចិត្តជាក់លាក់មួយ ទាក់ទងនឹងសមត្ថភាពរបស់ជនជាប់ចោទក្នុងការជួយដល់មេធាវី ដូចជាការពិនិត្យអំពីការចងចាំស្វ័យជីវប្រវត្តិរបស់ជនជាប់ចោទ ជាដើម។

២. គាត់ពុំបានធ្វើការវាយតម្លៃជាលក្ខណៈប្រព័ន្ធអំពីសមត្ថភាពនៃការយកចិត្តទុកដាក់ ការផ្ចង់អារម្មណ៍ ភាសា និងមុខងារប្រតិបត្តិរបស់ជនជាប់ចោទ ទាក់ទងនឹងភាពអំណត់របស់ជនជាប់ចោទចំពោះការហេវហត់អស់កម្លាំង និងការឈឺចុកចាប់ នៅពេលដែលសវនាការចេះតែបន្តធ្វើ និងនៅពេលដែលភាពស្មុគស្មាញនៃព័ត៌មានចេះតែកើនឡើង។

៣. គាត់បានបដិសេធទាំងស្រុងអំពីផលរំខានដែលអាចមានពីការប្រើប្រាស់ឱសថ ដោយផ្អែកតាមការសន្មតដោយឯកឯង ដែលថាដោយសារតែឱសថដែលជនជាប់ចោទប្រើប្រាស់ ពុំមានការផ្លាស់ប្ដូរ ទើបជាតិពុលដែលបញ្ចេញបន្តិចម្ដងៗក្នុងកម្រិតតិច ប៉ុន្តែគួរឲ្យកត់សម្គាល់ តាមជាលិកាប្រសាទទាក់ទងនឹងការប្រើប្រាស់ឱសថ អាចត្រូវបានបណ្ដេញចេញ ឬអាចត្រូវបានកត់សម្គាល់ឃើញដោយវេជ្ជបណ្ឌិតព្យាបាលជនជាប់ចោទ។

ផ្អែកលើបទពិសោធន៍របស់ខ្ញុំអស់រយៈពេលចំនួនជាង ៣០ ឆ្នាំ ជាអ្នកជំនាញវិកលវិទ្យានីតិវេជ្ជសាស្ត្រក្នុងវិស័យសិក្សាស្រាវជ្រាវ និងដែលបានការទទួលស្គាល់ពីតុលាការ ខ្ញុំសូមអះអាងថាវិធីសាស្ត្ររបស់វេជ្ជបណ្ឌិត Campbell ស្ថិតក្នុងលំដាប់ថ្នាក់ដែលពុំអាចជឿជាក់បានខ្លាំងជាងគេ។ យើងអាចប្រមើលឃើញថាភាពពុំអាចឲ្យជឿជាក់បាននេះ ពុំគោរពដល់សិទ្ធិរបស់ជនជាប់ចោទដែលបាត់បង់សមត្ថភាព ក្នុងការមានលទ្ធភាពជួយដល់មេធាវីក្នុងតុលាការនេះឡើយ។ ខ្ញុំសូមភ្ជាប់មកជាមួយនូវប្រវត្តិរូបវិជ្ជាជីវៈរបស់ខ្ញុំចំនួន ១ ច្បាប់។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ

ហត្ថលេខា

Harold J. Bursztrajn, M.D.